# ១០០ នរណាជាព្រះជាម្ចាស់?

យ៉ូហាន ១ - កូឡុស ១

កាលពីយូរយារ លង់ណាស់មកហើយ
គ្មានអ្វីសោះឡើយ តែមានព្រះធំ
គឺគ្មានប្រុសស្រី ឋានលោកឋានសួគ៌
ថ្ងៃអាប់រស្មី ខ្វះផ្កាយរង្សី
តែព្រះគង់នៅ ។

និស្ស័យព្រះអង្គ ពីដើមសម័យ
ក្នុងមួយមានបី ជាអាថ៌កំបាំង
ព្រះស្រាយប្រស្នា ដ៏សែនជ្រាលជ្រៅ
ជាព្រះបីតា ជាព្រះបុត្រា
ហើយព្រះវិញ្ញាណ ។

ព្រះជាម្ចាស់ខ្ពស់ ភ្លឺថ្លាពិសិដ្ឋ
អំណាចស័ក្តិសិទ្ធ ប្រែប្រួលមិនបាន
គ្មានដើម គ្មានចុង រស់រានរហូត
វិញ្ញាណទាំងស្រុង នៅទីសូន្យសុង
ហៀបនឹងបង្កើត ។

ជីវិតរង់ចាំ ក្នុងដួងហរទ័យ
បំណងចិត្តនៃ ព្រះដ៏ឧត្តម
ចាំព្រះប្រសាសន៍ មួយម៉ាត់ស្រដី
ទើបកើតរហ័ស លេចមកយ៉ាងក្រាស
ពាសពេញសកល ។

គ្រប់សព្វទាំងអស់ ដែលយើងមើលឃើញ
ត្រូវបានអញ្ជើញ ដោយព្រះជាម្ចាស់
អ្វីគ្មានរូបរាង សម្លឹងពុំបាន
គឺភពវិញ្ញាណ ដោយព្រះសូរសៀង
ក៏កើតមកដែរ!

## ១០១ ព្រះជាម្ចាស់ហៅមនុស្សទាំងអស់

កិច្ចការ ១៧:២២-៣១ (សំរួលទៅតាមសភាពការន៍នៅកម្ពុជាសព្វថ្ងៃនេះ)

អស់លោកអ្នកនៅប្រទេសកម្ពុជាអើយ! ខ្ញុំមើលឃើញថាលោកអ្នកនិយមសាសនាខ្លាំងណាស់ ពេលខ្ញុំដើទៅមកក្នុងប្រទេសនេះ ខ្ញុំឃើញមានរូបបដិមាជាច្រើនដែលអស់លោកគោរពបូជា ហើយខ្ញុំក៏បានឃើញមានវត្តអារាមជាច្រើនដែរ។ ប៉ុន្តែខ្ញុំនាំដំណឹងមកប្រាប់អស់លោកអំពីព្រះដែលលោកមិនទាន់ស្គាល់ ជាព្រះដ៏មានអំណាចនិងបារមីខ្ពស់បំផុត! ព្រះជាម្ចាស់ដែលបានបង្កើតពិភពលោក ព្រះអង្គជាព្រះអម្ចាស់នៃស្ថានសួគ៌ និង ព្រះអម្ចាស់នៃផែនដី ព្រះអង្គមិនអាស្រ័យនៅក្នុងព្រះវិហារដែលមនុស្សសង់នោះឡើយ ហើយព្រះអង្គក៏មិនត្រូវការអោយមនុស្សបីបាច់ថែរក្សាព្រះអង្គដែរ ព្រោះព្រះអង្គទេតើដែលបានអោយជីវិត អោយដង្ហើម និង អោយរបស់សព្វគ្រប់ទាំងអស់មកមនុស្ស។ ព្រះអង្គបានធ្វើអោយជាតិសាសន៍នានាកើតចេញមកពីមនុស្សតែម្នាក់ ហើយអោយគេរស់នៅពាសពេញលើផែនដីទាំងមូល។ ព្រះអង្គបានកំណត់ទុកជាមុននូវសម័យកាល និង ព្រំដែនរបស់ប្រជាជាតិនិមួយៗ ហើយត្រួតត្រាលើប្រវត្តិសាស្តរបស់គេដែរ។ ព្រះជាម្ចាស់ធ្វើដូច្នេះដើម្បីអោយគេស្វែងរកព្រះអង្គ ហើយបើគេខំព្យាយាមរកព្រះអង្គមែននោះ គេមុខជានឹងរកព្រះអង្គឃើញ។ តាមពិត ព្រះជាម្ចាស់មិនឋិតនៅឆ្ងាយពីយើងម្នាក់ៗទេ ព្រោះយើងរស់នៅ មានចលនា និង មានជីវិតនៅក្នុងព្រះអង្គ។ ដូច្នេះ ប្រសិនបើព្រះជាម្ចាស់បានបង្កើតមនុស្សទាំងអស់មែន យើងមិនត្រូវគិតថាព្រះអង្គមានរាងដូចរូបសំណាក ធ្វើពីមាស ប្រាក់ ឬថ្ម ដែលបានធ្វើឡើង តាមការនឹកឃើញរបស់មនុស្សនោះឡើយ។ ព្រះជាម្ចាស់មិនប្រកាន់ទោសមនុស្សលោក ក្នុងសម័យមុន ដែលគេធ្វើបែបនេះទាំងមិនដឹងខ្លួនទេ តែឥឡូវនេះ ព្រះអង្គកំពុងតែហៅមនុស្សទាំងអស់ដែលរស់នៅគ្រប់ទីកន្លែង អោយគេកែប្រែចិត្តគំនិត! ពីព្រោះព្រះអង្គបានកំណត់ថ្ងៃមួយទុក ដើម្បីកាត់ទោសមនុស្សដោយត្រឹមត្រូវ នោះតាមរយៈបុរសម្នាក់ដែលព្រះអង្គបានតែងតាំង។ ព្រះជាម្ចាស់បានផ្តល់ភស្តុតាងដល់មនុស្សទាំងអស់អំពីការកាត់ទោសនោះ ដោយលើកបុរសនោះអោយរស់ពីសេចក្តីស្លាប់ឡើងវិញ!

# ១០២ ស្ថានសួគ៌ និង ស្ថាននរក

យ៉ូប ៣៨ - វិវរណៈ ២០

កាលពីយូរលង់ណាស់មកហើយ ព្រះជាម្ចាស់បង្កើតស្ថានសួគ៌ជារាជបល្ល័ង្កសំរាប់ សោយរាជ្យលើអ្វីៗដែលព្រះអង្គនឹងបង្កើតឡើង។ ស្ថានសួគ៌ជាកន្លែងភ្លឺរុងរឿង ស្អាតនិងបរិសុទ្ធជាទីបំផុតពោរពេញទៅដោយសេចក្តីសុខសាន្ត។ ព្រះជាម្ចាស់ក៏បានបង្កើតទេវតាយ៉ាងច្រើន រាប់មិនអស់ទេ គឺដើម្បីធ្វើជាអ្នកបំរើរបស់ព្រះអង្គ។

ក្រោយមក មានទេវតាម្នាក់ឈ្មោះមារសាតាំង ដែលព្រះអង្គបានបង្កើតអោយមានទួនាទីសំខាន់ និងអំណាចច្រើន គាត់បានអួតខ្លួននិងប្រាថ្នាចង់ធ្វើជាព្រះជាម្ចាស់តែម្តង។ គាត់កុហកនិងបោកបញ្ឆោតទេវតាមួយចំនួនធំ គឺមួយភាគបីនៃទេវតាទាំងអស់អោយចូលដៃជាមួយគាត់និងប៉ះបោរប្រឆាំងនឹងព្រះជាម្ចាស់ដែលមានអំណាចខ្ពស់បំផុត។

ពេលនោះ មានសង្គ្រាមនៅស្ថានសួគ៌ តែមារសាតាំង និង ពួកទេវតារបស់គាត់ មិនអាចឈ្នះលើទេវតាដែលនៅស្មោះត្រង់នឹងព្រះជាម្ចាស់នោះទេ។ ព្រះអង្គថ្កោលទោសពួកទេវតាអាក្រក់ទាំងនោះដែលបានប៉ះបោរ ហើយបានរៀបចំកន្លែងមួយសំរាប់ពួកគេទទួលទណ្ឌកម្មអស់កល្បជានិច្ច គឺស្ថាននរក ដែលមានរាងដូចបឹងភ្លើងនិងស្ពាន់ធ័រកំពុងឆេះ។ ថ្ងៃមួយព្រះជាម្ចាស់នឹងបោះគេចូលទៅក្នុងបឹងភ្លើងនោះជាស្ថារពរ។ ប៉ុន្តែព្រះអង្គនៅបង្អង់ចាំបំណងចិត្តរបស់ព្រះអង្គបានសំរេចតាមរយៈពួកគេសិន ទើបគេនឹងទទួលការជំនុំជំរះ។

ដូច្នេះ មារសាតាំងនិងពួកទេវតារបស់វា បានក្លាយជាសត្រូវនឹងព្រះជាម្ចាស់ ហើយកំពុងរង់ចាំទណ្ឌកម្មដែលមិនចេះអស់មិនចេះហើយនោះ។ មារសាតាំងមានឈ្មោះដែរថា នាគ ពស់ ហើយឪពុកនៃពួកកុហក ហើយទេវតារបស់វាជាវិញ្ញាណអាក្រក់ ព្រាយបិសាច និងអារក្សអ្នកតាទាំងអស់ដែលធ្វើបាបនិងជិះជាន់មនុស្សដែលជាកូនព្រះជាម្ចាស់ រហូតមកដល់សព្វថ្ងៃនេះ។

ឥឡូវនេះ លំហអាកាសជាទីលំនៅរបស់ពួកគេ តែថ្ងៃមួយព្រះជាម្ចាស់នឹងបោះបង់ចោលពួកគេ ចូលទៅក្នុងបឹងភ្លើងជាស្ថារពរ ហើយពួកគេនឹងទទួលទណ្ឌកម្មអស់កល្បជាអង្វែងតរៀងទៅ។

# ១០៣ កំណើតពិភពលោក

លោកុប្បត្តិ ១

កាលពីដើមដំបូងបង្អស់ ព្រះជាម្ចាស់បង្កើតផ្ទៃមេឃនិងផែនដី។ នៅគ្រានោះ ផែនដីគ្មានរូបរាង និង នៅទទេ មានតែភាពងងឹតពីលើទឹក។ ព្រះជាម្ចាស់បានបង្គាប់ថា៖ «ចូរមានពន្លឺ!» ពន្លឺក៏កើតមានឡើង។ ព្រះជាម្ចាស់មើលឃើញថា ពន្លឺនោះល្អប្រសើរហើយ ព្រះអង្គក៏បានញែកពន្លឺចេញពីភាពងងឹត។ ព្រះជាម្ចាស់ហៅពន្លឺថា «ថ្ងៃ» និង ហៅភាពងងឹតថា «យប់»។ ពេលនោះគឺជាថ្ងៃទី១។

ព្រះជាម្ចាស់បានបង្គាប់ថា៖ «ចូរមានលំហ» នោះក៏កើតមានឡើង។ ព្រះអង្គហៅលំហនោះថា «មេឃ»។ ពេលនោះគឺជាថ្ងៃទី២។

ព្រះជាម្ចាស់បានបង្គាប់ថា៖ «ចូរអោយទឹកដែលនៅពីក្រោមមេឃផ្តុំគ្នានៅកន្លែងតែមួយ និងអោយផ្ទៃគោកលេចចេញមក!» នោះក៏កើតមានអញ្ចឹងមែន។ ព្រះអង្គហៅផ្ទៃគោកនោះថា «ដី» ហើយផ្ទៃទឹកថា «សមុទ្រ»។ ព្រះជាម្ចាស់មើលឃើញថា ដីនិងសមុទ្រល្អប្រសើរហើយ។ ព្រះអង្គបង្គាប់ទៀតថា៖ «ចូរមានព្រៃឈើនិងស្រូវផ្សេងៗដែលមានគ្រាប់ពូជ និងដើមឈើដែលមានផ្លែដុះចេញពីដីមក បង្កើតផលនៅលើផែនដី តាមពូជរបស់វា» នោះក៏កើតមានអញ្ចឹងមែន។ ព្រះជាម្ចាស់មើលឃើញថា អ្វីៗទាំងនោះល្អប្រសើរហើយ។ ពេលនោះគឺជាថ្ងៃទី៣។

ព្រះជាម្ចាស់បានបង្គាប់ថា៖ «ចូរមានដុំពន្លឺនៅលើមេឃ ដើម្បីញែកថ្ងៃចេញពីយប់ និងសំរាប់កំណត់ពេលវេលា ថ្ងៃ ឆ្នាំ និងរដូវកាល ហើយសំរាប់បំភ្លឺផែនដី» នោះក៏កើតមានអញ្ចឹងមែន។ ព្រះអង្គបានបង្កើតដុំពន្លឺធំពីរ អាធំជាងអោយបំភ្លឺពេលថ្ងៃ និងអាតូចជាងអោយបំភ្លឺពេលយប់។ ព្រះអង្គក៏បានបង្កើតផ្កាយទាំងអស់ដែរ។ ព្រះជាម្ចាស់មើលឃើញថា អ្វីៗទាំងនោះល្អប្រសើរហើយ។ ពេលនោះគឺជាថ្ងៃទី៤។

ព្រះជាម្ចាស់បានបង្គាប់ថា៖ «ចូរមានត្រីយ៉ាងច្រើនរស់រវើកនៅក្នុងទឹក និង មានបក្សាបក្សីហើរនៅលើមេឃ» នោះក៏កើតមានអញ្ចឹងមែន។ ព្រះអង្គបានបង្កើតសត្វទាំងអស់នោះ តាមពូជរបស់វា។ ព្រះជាម្ចាស់មើលឃើញថា សត្វទាំងនោះល្អប្រសើរហើយ។ ព្រះអង្គប្រទានពរដល់សត្វទាំងអស់នោះថា៖ «ចូរ

បង្កើតកូនចៅអោយបានកើនចំនួនច្រើនឡើង» ពេលនោះគឺជាថ្ងៃទី៥។

ព្រះជាម្ចាស់បានបង្គាប់ថា៖ «ចូរមានសត្វផ្សេងៗកើតចេញពីដី សត្វស្រុក សត្វព្រៃ សត្វលូនវារ តាមពូជរបស់វា» នោះក៏កើតមានអញ្ចឹងមែន។ ព្រះជាម្ចាស់មើលឃើញថាសត្វទាំងនោះល្អប្រសើរហើយ។ ព្រះជាម្ចាស់បានបង្គាប់ទៀតថា៖ «យើងបង្កើតមនុស្សជាតំណាងរបស់យើង មាននិស្ស័យដូចយើង ដើម្បីអោយគេមានអំណាចលើត្រីសមុទ្រ លើបក្សាបក្សី លើសត្វស្រុក និងសត្វព្រៃធំតូចនៅលើផែនដីទាំងមូល»។ ព្រះជាម្ចាស់បានបង្កើតមនុស្សជាតំណាងរបស់ព្រះអង្គ អោយមាននិស្ស័យដូចព្រះអង្គ ហើយព្រះអង្គបង្កើតគេ ជាបុរស ជាស្ត្រី ហើយបាននិយាយថា៖ «ចូរបង្កើតកូនចៅអោយបានកើនចំនួនច្រើនឡើងពាសពេញលើផែនដី ហើយត្រួតត្រាលើផែនដីទៅ។ ចូរមានអំណាចលើត្រីសមុទ្រ លើបក្សាបក្សី និង លើសត្វទាំងអស់នៅលើដី»។ ព្រះជាម្ចាស់ក៏និយាយទៀតថា៖ «មើល៍ យើងអោយគ្រាប់ស្រូវផ្សេងៗ និងផ្លែឈើគ្រប់ប្រភេទដល់កូនធ្វើជាអាហារ ហើយយើងក៏អោយស្មៅផ្សេងៗដល់សត្វទាំងអស់ ធ្វើជាអាហារដែរ» នោះក៏កើតមានអញ្ចឹងមែន។ ព្រះជាម្ចាស់មើលឃើញអ្វីៗទាំងអស់ដែលព្រះអង្គបានបង្កើតមកនោះ ថាល្អប្រសើរបំផុតហើយ។ ពេលនោះ គឺជាថ្ងៃទី៦។

មេឃនិងផែនដីចប់សព្វគ្រប់ហើយ។ នៅថ្ងៃទី៧ ព្រះជាម្ចាស់បង្ហើយកិច្ចការដែលព្រះអង្គបានធ្វើ ហើយព្រះអង្គក៏ឈប់សំរាកព្រមទាំងជូនពរដល់ថ្ងៃទី៧ និងញែកថ្ងៃនោះអោយបានពិសេស។

## ១០៤ មនុស្សដើមដំបូងបង្អស់

លោកុប្បត្តិ ២

ព្រះជាម្ចាស់បានយកដីមកសូនជាបុរស រួចព្រះអង្គផ្លុំដង្ហើមជីវិតតាមរន្ធច្រមុះគាត់ ហើយបុរសក៏មានជីវិតរស់ឡើង។

ព្រះជាម្ចាស់បានធ្វើសួនមួយក្នុងស្រុកអេដែន រួចយកបុរសដែលព្រះអង្គបានសូនទៅដាក់ក្នុងសួននោះ។ ព្រះជាម្ចាស់បានធ្វើអោយដើមឈើគ្រប់មុខដុះចេញពីដីមក មានផ្លែស្រស់ស្អាតនិងឆ្ងាញ់ហូបផង។ នៅកណ្តាលសួនក៏មានដើមឈើដែលផ្តល់ជីវិត និង ដើមឈើដែលនាំអោយស្គាល់ល្អស្គាល់អាក្រក់ដែរ។

មានទន្លេមួយហូរស្រោចសួន ហើយនៅក្នុងសួន ទន្លេនោះក៏បែកចេញជាបួន។

ព្រះជាម្ចាស់បានយកបុរសទៅដាក់ក្នុងសួនអេដែន ដើម្បីអោយគាត់ថែរក្សាសួននោះ។ ព្រះជាម្ចាស់បានបញ្ជាបុរសដូចតទៅ៖ «កូនអាចញ៉ាំផ្លែឈើណានៅក្នុងសួននេះបាន តែមិនត្រូវញ៉ាំផ្លែឈើពីដើមដែលនាំអោយស្គាល់ល្អ ស្គាល់អាក្រក់ឡើយ ព្រោះថ្ងៃណាកូនញ៉ាំផ្លែនោះ កូនមុខជាស្លាប់មិនខាន»។

ព្រះជាម្ចាស់បាននិយាយថា៖ «បើបុរសនៅតែឯងដូច្នេះ មិនល្អទេ។ យើងនឹងបង្កើតម្នាក់ទៀតអោយជួយ និង បានជាគ្នា»។ ព្រះជាម្ចាស់បាននាំសត្វទាំងអស់ដែលព្រះអង្គបានបង្កើត មកអោយបុរសដាក់ឈ្មោះអោយវា។ ដូច្នេះ សត្វទាំងអស់មានឈ្មោះតាមដែលបុរសដាក់អោយ ប៉ុន្តែ គាត់មិនឃើញសត្វណាមួយដែលអាចជួយ និង យកមកធ្វើជាគ្នាបានឡើយ។

ដូច្នេះ ព្រះជាម្ចាស់បានធ្វើអោយបុរសសន្លប់ ហើយព្រះអង្គយកឆ្អឹងជំនីរមួយរបស់គាត់ចេញមក រួចភ្ជិតសាច់ទៅវិញ។ ព្រះជាម្ចាស់យកឆ្អឹងជំនីរដែលព្រះអង្គបានហូតចេញពីបុរស មកធ្វើជាស្ត្រី រួចព្រះអង្គនាំនាងមកជួបគាត់។ បុរសក៏និយាយថា៖ «នេះពិតជាឆ្អឹងដែលកើតចេញមកពីឆ្អឹងខ្ញុំ ជាសាច់ដែលកើតចេញមកពីសាច់ខ្ញុំដែរ ខ្ញុំនឹងហៅនាងថា "ស្ត្រី"»។

ហេតុនេះ កាលណាបុរសចាកចេញពីឪពុកម្ដាយ ទៅរួមរស់ជាមួយប្រពន្ធរបស់ខ្លួន អ្នកទាំងពីរត្រឡប់ទៅជារូបកាយតែមួយ។

ពេលនោះ បុរស និង ប្រពន្ធរបស់គាត់ នៅខ្លួនទទេទាំងពីរនាក់ តែគេមិនអៀនខ្មាសទេ។

# ១០៥ មនុស្សដើមដំបូងបង្អស់មិនស្ដាប់បង្គាប់ព្រះជាម្ចាស់

លោកុបត្តិ ៣

ពស់ជាសត្វមួយមានកលល្បិចជាងគេ ក្នុងចំណោមសត្វព្រៃទាំងអស់ដែលព្រះជាម្ចាស់បង្កើតមក។ មារសាតាំងនិយាយទៅកាន់ស្ត្រីតាមរយៈពស់ថា៖ «តើ ព្រះជាម្ចាស់ពិតជាបានបង្គាប់ថា អ្នកមិនត្រូវញ៉ាំផ្លែឈើណាដែលនៅក្នុងសួនមែនឬ?»។ ស្ត្រីឆ្លើយទៅពស់វិញថា៖ «ទេ! យើងអាចញ៉ាំផ្លែឈើទាំងអស់នៅក្នុងសួនបាន លើកលែងតែដើមឈើដែលស្ថិតនៅកណ្ដាលសួននោះវិញ ព្រោះព្រះជាម្ចាស់បានហាមថា "កុំញ៉ាំផ្លែវា ក៏កុំប៉ះពាល់ដែរ! បើមិនស្ដាប់ទេ អ្នកទាំងពីរនឹងស្លាប់ជាមិនខាន"»។ ដល់ពេលហើយ ពស់ប្រាប់ស្ត្រីថា៖ «ទេ! អ្នកនឹងមិនស្លាប់ទេ។ តែព្រះជាម្ចាស់ដឹងថា កាលណាអ្នកញ៉ាំផ្លែឈើនោះ អ្នកនឹងបានភ្លឺស្វាង ហើយអ្នកនឹងបានដូចព្រះដែលស្គាល់ល្អ ស្គាល់អាក្រក់ជាមិនខាន»។

ស្ត្រីមើលទៅដើមឈើ ឃើញផ្លែវាគួរអោយឆ្ងាញ់ ស្រស់ល្អហើយអាចធ្វើអោយមានប្រាជ្ញាទៀតផង នាងក៏បេះផ្លែមកញ៉ាំ ហើយចែកអោយប្ដីដែលនៅជាមួយ ហើយប្ដីក៏ញ៉ាំដែរ។ ស្រាប់តែពួកគេបានភ្លឺស្វាង ហើយដឹងថា គេនៅខ្លួនទទេ។ ពួកគេក៏បេះស្លឹកល្វាមកបិតបាំងកាយ។

ក្រោយមក គេបានឮសំលេងរបស់ព្រះជាម្ចាស់នៅក្នុងសួន បុរសនិងស្ត្រីក៏នាំគ្នារត់ពួនក្រោយដើមឈើក្នុងសួន កុំអោយព្រះជាម្ចាស់មើលឃើញ។ ព្រះជាម្ចាស់បានហៅបុរសថា៖ «កូននៅឯណា?» គាត់ឆ្លើយទៅព្រះអង្គវិញថា៖ «ខ្ញុំបានឮសំលេងរបស់ព្រះអង្គនៅក្នុងសួន ខ្ញុំភ័យណាស់ ព្រោះខ្ញុំនៅខ្លួនទទេ»។ ព្រះអង្គសួរទៀតថា៖ «នរណាប្រាប់កូនថាកូននៅខ្លួនទទេដូច្នេះ? តើកូនបានញ៉ាំផ្លែឈើដែលយើងហាមនោះឬ? បុរសឆ្លើយថា៖ «ស្ត្រីដែលព្រះអង្គបង្កើតអោយនៅជាមួយខ្ញុំនោះ បានអោយផ្លែឈើខ្ញុំ ហើយខ្ញុំក៏ញ៉ាំដែរ»។ ព្រះជាម្ចាស់សួរស្ត្រីថា៖ «ម្ដេចក៏នាងធ្វើដូច្នេះ?» ស្ត្រីឆ្លើយថា៖ «ពស់បានមកបញ្ឆោតខ្ញុំ ហើយខ្ញុំក៏ញ៉ាំផ្លែឈើនោះទៅ»។

ព្រះជាម្ចាស់ស្ដីអោយសត្វពស់ថា៖ «ឯងត្រូវបណ្ដាសាហើយ! ឯងត្រូវលូននឹងពោះ ហើយស៊ីតែធូលីដីអស់មួយជីវិត។ យើងនឹងធ្វើអោយឯងនិងស្ត្រី កូនចៅឯងនិងកូនចៅស្ត្រី ក្លាយទៅជា

សត្រូវនឹងគ្នា កូនចៅនាងនឹងជាន់ក្បាលរបស់ឯង ហើយឯងនឹងចឹកកែងជើងរបស់កូនចៅនាង» ។

ព្រះអង្គស្ដីអោយស្ត្រីថា៖ «នៅពេលនាងមានផ្ទៃពោះ យើងនឹងធ្វើអោយនាងរងទុក្ខលំបាកយ៉ាងខ្លាំង នាងនឹងសំរាលកូនទាំងឈឺចុកចាប់។ នាងនឹងស្រឡាញ់ប្ដី តែគាត់នឹងធ្វើជាម្ចាស់លើនាង»។

ព្រះអង្គស្ដីអោយបុរសថា៖ «ដោយកូនបានស្ដាប់តាមពាក្យប្រពន្ធ ហើយញុំាផ្លែឈើដែលយើងហាមប្រាមនោះ ដីនឹងត្រូវបណ្ដាសាព្រោះតែកូន។ ដូច្នេះ កូននឹងកាប់គាស់ដីចិញ្ចឹមជីវិតយ៉ាងវេទនាជារៀងរាល់ថ្ងៃអស់មួយជីវិត។ ដីនឹងដុះចេញជាបន្លានិងអញ្ចាញ កូននឹងរកស៊ីចិញ្ចឹមជីវិតទាំងបង្ហូរញើស រហូតដល់ថ្ងៃដែលកូនត្រូវត្រឡប់ទៅជាដីវិញ»

បុរស (ដែលមានឈ្មោះថា "អដាំ") ដាក់ឈ្មោះអោយប្រពន្ធថា "អេវ៉ា" ព្រោះនាងជាម្ដាយរបស់មនុស្សទាំងអស់។ ព្រះជាម្ចាស់បានយកស្បែកសត្វមកធ្វើជាខោអាវអោយអដាំនិងអេវ៉ា ហើយព្រះអង្គបាននិយាយថា៖ «ឥឡូវនេះ មនុស្សក៏ស្គាល់ល្អស្គាល់អាក្រក់ដូចយើងដែរ ដូច្នេះយើងនឹងរារាំងគេ កុំអោយបេះផ្លែពីដើមឈើដែលផ្ដល់ជីវិតទៀតឡើយ ក្រែងគេញុំាទៅ ហើយមានជីវិតអស់កល្បជានិច្ច»។

ព្រះជាម្ចាស់ក៏បណ្ដេញមនុស្សចេញពីសួនអេដែន រួចដាក់ទេវតាដែលកាន់ដាវភ្លើងការពារផ្លូវចូលសួន មិនអោយមនុស្សចូលទៅកាន់ដើមឈើដែលផ្ដល់ជីវិតនោះបានទៀតឡើយ។

# ១០៦ ពីព្រេងនាយរហូតដល់ព្រះសង្គ្រោះចុះពីស្ថានសួគ៌

លោកុប្បត្តិ — ម៉ាថាយ

លោកអដាំនិងនាងអេវ៉ា ត្រូវបានបណ្តេញចេញពីសួនអេដែន ហើយផ្តាច់ចេញពីដើមឈើដែលផ្តល់ជីវិត។ ដូច្នេះ ចាប់ពីពេលនោះមក ពួកគេចាប់ផ្តើមរងទុក្ខ កើតជំងឺ និងឈឺចុកចាប់រហូតដល់ស្លាប់ ហើយអ្វីៗដែលអាក្រក់បានរាលដាលនៅក្នុងពិភពលោក។ ការណ៍ទាំងអស់នោះបានកើតឡើង ជាលទ្ធផលនៃការមិនស្តាប់បង្គាប់ព្រះជាម្ចាស់ ជាអ្វីដែលហៅថា «អំពើបាប»។

នៅពេលនោះ លោកអដាំរួមរស់ជាមួយនាងអេវ៉ាជាប្រពន្ធ នាងមានផ្ទៃពោះ សំរាលបានកូនទីមួយ ក្រោយមកបានបង្កើតកូនប្រុស កូនស្រីជាច្រើន។ ដូច្នេះ មនុស្សលោកទាំងអស់ គឺគ្រប់ជាតិសាសន៍ បានកើតឡើងជាកូនចៅរបស់លោកទាំងពីរ ហើយមនុស្សគ្រប់ៗរូប ទាំងចាស់ទាំងក្មេង ក៏មានបាប រងទុក្ខវេទនា ព្រមទាំងស្លាប់ដូចគេដែរ។ យើងទាំងអស់គ្នាត្រូវបានផ្តាច់ចេញពីទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដែលជាប្រភពនៃជីវិត ហើយត្រូវទទួលការវិនិច្ឆ័យ អោយវិនាសដោយទណ្ឌកម្មនៅក្នុងបឹងភ្លើងជារៀងរហូត នោះដោយព្រោះបាបរបស់យើង។

ក្រោយមក មនុស្សលោកព្យាយាមដោះស្រាយបញ្ហានេះដោយខ្លួនឯង ចង់លុបលាងបាបចេញនិងរកជីវិតអមតៈ តែដោះមិនរួចទេ។ គេនាំគ្នាបូជាសត្វ ថ្វាយដង្វាយដុតផ្សេងៗ ធ្វើបុណ្យ ធ្វើទាន គោរពសំពះព្រះអាទិត្យនិងព្រះខែ ព្រមទាំងសែនជីដូនជីតា និងអារកអ្នកតា តែបាបនិងសេចក្តីស្លាប់នៅជាប់ដដែល។ គេនាំគ្នាយកមាស ប្រាក់ និងឈើមកឆ្លាកធ្វើជាព្រះ រួចគោរពនិងបន់ស្រន់រូបទាំងនោះ។ ប៉ុន្តែ ការខំប្រឹងប្រែងទាំងអស់របស់មនុស្ស ឥតបានការអ្វីសោះ ពីព្រោះ ក្រៅពីព្រះជាម្ចាស់ គ្មានអ្នកណាដែលអាចដកហូតបាបបាន។

នៅពេលដែលព្រះជាម្ចាស់មើលឃើញមនុស្សវេទនាអញ្ចឹង ព្រះអង្គអាណិតមេត្តា និងស្រឡាញ់មនុស្សលោកជាខ្លាំង ក៏បានសន្យាតាមរយៈព្យាការីរបស់ព្រះអង្គថា ព្រះអង្គនឹងចាត់ព្រះបុត្រាដែលបរិសុទ្ធ និងដែលគ្មានបាបសោះ អោយមកសង្គ្រោះនិងស្រោចស្រង់មនុស្សលោកអោយរួចពីបាបនិងសេចក្តីស្លាប់។ ព្រះជាម្ចាស់បានសន្យាថា ព្រះអង្គនឹងចុះមកពីស្ថានសួគ៌ ដើម្បីដោះលែងមនុស្សអោយរួចពីអំណាចនៃមារសាតាំង ហើយលើកលែងទោសបាបរបស់ពួកគេ ប្រយោជន៍អោយបានជីវិតអស់កល្បជានិច្ច។

# ២០១ ព្រះបុត្រាមកផែនដី

ម៉ាថាយ ១ - លូកា ២

អស់រយៈពេលរាប់ពាន់ឆ្នាំ ក្រោយពេលលោកអដាំនិងនាងអេវ៉ា ចេញពីសួនអេដែនមក មានស្ត្រីម្នាក់ឈ្មោះម៉ារី ជាគូដណ្ដឹងរបស់បុរសម្នាក់ឈ្មោះយ៉ូសែប។ មុនពេលអ្នកទាំងពីររួមភេទជាមួយគ្នា នាងម៉ារីមានផ្ទៃពោះ ដោយសារព្រះវិញ្ញាណរួចទៅហើយ។

លោកយ៉ូសែបជាប្ដីជាមនុស្សល្អ ក៏បានសំរេចចិត្តផ្ដាច់ពាក្យដោយស្ងាត់ៗ កុំអោយនាងបាក់មុខ។ ពេលលោកកំពង់គិតអញ្ចឹង ក៏ស្រាប់តែគាត់យល់សប្តឃើញទេវតាពីព្រះជាម្ចាស់មកប្រាប់ថា៖ « យ៉ូសែប! កុំខ្លាចនឹងទទួលនាងម៉ារីមកធ្វើជាប្រពន្ធអី! កូនប្រុសដែលនៅក្នុងផ្ទៃនាង កើតមកពីព្រះវិញ្ញាណទេ។ នាងនឹងសំរាលបានកូនប្រុសមួយ ហើយលោកត្រូវដាក់ឈ្មោះថា "យេស៊ូ" បុត្រានោះនឹងស្រោចស្រង់រាស្ត្រព្រះអង្គអោយរួចពីបាបរបស់គេ!»

ដល់ពេលហើយ យ៉ូសែបភ្ញាក់ឡើង ហើយក៏ធ្វើតាមបង្គាប់ព្រះជាម្ចាស់ទៅ គឺលោកទទួលនាងម៉ារីធ្វើជាប្រពន្ធ តែមិនបានរួមភេទជាមួយនាង រហូតដល់នាងសំរាលព្រះបុត្រាដែលមានឈ្មោះថា « យេស៊ូ» ។

នៅពេលនោះ ស្ដេចបង្គាប់អោយប្រជាជនទាំងអស់ចុះឈ្មោះតាមស្រុកកំណើតរៀងៗខ្លួន លោកយ៉ូសែបនិងនាងម៉ារីជាប្រពន្ធក៏ធ្វើដំណើទៅស្រុកកំណើត ដើម្បីចុះឈ្មោះក្នុងបញ្ជីដែរ។ នៅពេលទៅដល់ស្រុកកំណើត នាងម៉ារីក៏គ្រប់ខែហើយ នាងក៏បានសំរាលកូនច្បង ហើយរុំកូននោះនឹងសំពត់ រួចផ្ដេកក្នុងស្នូកសត្វ ពីព្រោះមិនសល់កន្លែងក្នុងផ្ទះសំណាក់សោះ។

ការណ៍នេះកើតឡើង ស្របតាមពាក្យដែលព្រះជាម្ចាស់បានសន្យាតាមរយៈអ្នកបំរើរបស់ព្រះអង្គថា « មើល៍! ស្ត្រីព្រហ្មចារីនឹងមានផ្ទៃពោះនិងសំរាលបានបុត្រាមួយ ដែលគឺជាព្រះជាម្ចាស់ដែលនៅជាមួយយើង។»

# ២០២ ព្រះយេស៊ូមានអំណាចលើធម្មជាតិនិងវិញ្ញាណអាក្រក់

ម៉ាកុស ៤:៣៥ - ៥:២០

នៅល្ងាចមួយ ព្រះយេស៊ូបាននិយាយទៅពួកសិស្សរបស់ព្រះអង្គថា៖ «តោះ! យើងឆ្លងសមុទ្រទៅត្រើយម្ខាង»។ ពួកសិស្សចេញពីហ្វូងមនុស្ស ហើយអុំទូកដែលមានព្រះយេស៊ូនៅក្នុងនោះ។ ស្រាប់តែមានខ្យល់ព្យុះបក់បោកយ៉ាងខ្លាំង ហើយរលកក៏បោកប៉ះនឹងទូក បណ្ដាលអោយទឹកចូលស្ទើរពេញ រីឯព្រះយេស៊ូវិញ ក៏គេងលក់លើខ្នើយនៅកន្សៃទូក។ ពួកសិស្សដាស់ព្រះអង្គថា៖ «លោកគ្រូ យើងស្លាប់ឥឡូវហើយ! លោកមិនអើពើទេឬ?»។ ព្រះយេស៊ូក្រោកឡើង បញ្ជាខ្យល់ព្យុះនិងសមុទ្រថា៖ «ស្ងប់ស្ងៀមទៅ!» ពេលនោះខ្យល់ព្យុះក៏ស្ងប់ហើយផ្ទៃទឹកក៏រាបស្មើដែរ។ បន្ទាប់មក ព្រះយេស៊ូសួរទៅពួកសិស្សថា៖ «ម៉េចក៏ភិតភ័យអញ្ចឹង? តើគ្មានជំនឿទេឬ?»។ ពួកសិស្សកោតខ្លាចជាខ្លាំង ហើយសួរគ្នាទៅវិញទៅមកថា៖ «តើលោកនេះជានរណាបានជាខ្យល់ព្យុះ និង សមុទ្រស្ដាប់បង្គាប់លោកដូច្នេះ?»។

ព្រះយេស៊ូនិងពួកសិស្សបានទៅដល់ត្រើយម្ខាង។ កាលព្រះអង្គឡើងពីទូកភ្លាម មានបុរសម្នាក់ខ្មោចចូល ចេញពីទីបញ្ចុះសពដើរតំរងមករកព្រះអង្គ។ បុរសនេះស្នាក់នៅតែតាមទីបញ្ចុះសព ហើយគ្មាននរណាអាចចងគាត់បានឡើយ ទោះជាយកច្រវាក់មកចងក៏មិនជាប់ដែរ។ គេដាក់ខ្នោះជើង និង យកច្រវាក់ចងគាត់ច្រើនដង ប៉ុន្តែគាត់នៅតែកាច់បំបាក់ច្រវាក់និងខ្នោះទាំងនោះជានិច្ច គ្មាននរណាអាចបង្ក្រាបគាត់បានឡើយ។ ទាំងយប់ទាំងថ្ងៃគាត់ចេះតែស្រែក និង យកថ្មមកអារសាច់ខ្លួនឯងថែមទៀតផង។ កាលគាត់ឃើញព្រះយេស៊ូពីចម្ងាយ ក៏រត់មកក្រាបគោរពព្រះអង្គ។ ព្រះយេស៊ូបញ្ជាវាថា៖ «នែខ្មោចបីសាច ចូរចេញពីអ្នកនេះទៅ!» ខ្មោចស្រែកថា៖ «ឱព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុតអើយ តើព្រះអង្គចង់ធ្វើអ្វីខ្ញុំ? សូមអង្វរកុំធ្វើទុក្ខទោសខ្ញុំអី!» ព្រះយេស៊ូសួរខ្មោចថា៖ «ឯងឈ្មោះអី?» ខ្មោចក៏ឆ្លើយថា៖ «ខ្ញុំឈ្មោះកងទ័ព ព្រោះយើងខ្ញុំមានគ្នាច្រើន»។

នៅក្បែរនោះ មានជ្រូកមួយហ្វូងធំកំពុងរកស៊ីនៅតាមចង្កេះភ្នំ។ ពួកខ្មោចក៏អង្វរព្រះយេស៊ូទៀតថា៖ «សូមកុំបណ្ដេញយើងខ្ញុំចេញពីស្រុកនេះអី តែសូមបញ្ជូនយើងខ្ញុំអោយទៅចូលក្នុងជ្រូកទាំងនោះទៅ!» ព្រះយេស៊ូក៏យល់ព្រម។ ខ្មោចចេញពីបុរសនោះ ទៅចូលក្នុងហ្វូងជ្រូកដែលមានចំនួនពីពាន់ក្បាល វាក៏បោលចុះតាមជំរាលភ្នំតំរង់ទៅសមុទ្រលង់ទឹកងាប់អស់។ ពួកអ្នកថែរក្សាហ្វូងជ្រូករត់ទៅប្រាប់មនុស្សនៅគ្រប់កន្លែងអំពីរឿងនេះ ហើយមនុស្ស

យ៉ាងច្រើននាំគ្នាមកមើលការណ៍នោះ។ គេឃើញព្រះយេស៊ូ និងឃើញបុរសដែលមានខ្មោចកងទ័ពចូលកាលពីមុន អង្គុយស្លៀមមានខោអាវ ហើយដឹងស្មារតីឡើងវិញ គេក៏ភ័យខ្លាចជាខ្លាំង។

ដូច្នេះមនុស្សទាំងអស់ក៏សូមព្រះយេស៊ូអោយចេញពីស្រុករបស់គេ ហើយនៅពេលដែលព្រះយេស៊ូកំពុងចុះទូក ព្រះអង្គក៏ប្រាប់បុរសដែលបានដោះលែងពីខ្មោចកង់ទ័ពនោះថា÷ « ចូរអ្នកត្រលប់ទៅផ្ទះ ទៅនៅជាមួយក្រុមគ្រួសារវិញចុះ ហើយរៀបរាប់ការណ៍ទាំងអស់ដែលព្រះអម្ចាស់បានធ្វើអោយអ្នកដោយចិត្តអាណិតមេតា» ។

បុរសនោះក៏ចេញទៅ ហើយចាប់ផ្តើមប្រកាសអំពីការទាំងអស់ដែលព្រះយេស៊ូបានធ្វើអោយគាត់ ហើយមនុស្សទាំងអស់រំភើបចិត្តនិងឆ្ងល់គ្រប់គ្នា។

# ២០៣ ព្រះយេស៊ូមានអំណាចអត់ទោសបាប

លូកា ៥:១៧_២៦

បន្ទាប់មក ព្រះយេស៊ូទៅដល់ត្រើយម្ខាងជាមួយសិស្សរបស់ព្រះអង្គ។ ព្រះយេស៊ូចាប់ផ្ដើមបង្រៀនមនុស្ស ហើយមានពួកកាន់សាសនាមកអង្គុយស្ដាប់ព្រះអង្គដែរ។ ព្រះយេស៊ូពេញដោយអំណាចរបស់ព្រះជាម្ចាស់ ក៏មើលអ្នកជំងឺអោយបានជា។ ពេលនោះស្រាប់តែមានគេសែងបុរសខ្វិនដៃខ្វិនជើងម្នាក់មកដល់ គេមានបំណងនាំអ្នកខ្វិននោះចូលទៅជិតព្រះយេស៊ូ។ ប៉ុន្តែដោយមានមនុស្សច្រើនពេកគេមិនអាចចូលទៅជិតព្រះអង្គបានឡើយ ដូច្នេះគេក៏សែងអ្នកខ្វិនឡើងទៅលើដំបូលផ្ទះ បកក្បឿង សំរូតគាត់ចុះមកកណ្ដាលចំណោមមនុស្ស នៅចំពីមុខព្រះយេស៊ូ។

ពេលព្រះយេស៊ូឃើញជំនឿរបស់អ្នកទាំងនោះ ព្រះអង្គនិយាយទៅអ្នកខ្វិនថា៖ «មិត្តអើយ ខ្ញុំអត់ទោសអោយអ្នករួចពីបាបហើយ!»។ អ្នកកាន់សាសនានឹកគិតក្នុងចិត្តថា យេស៊ូនេះពិតជាស្មានថាខ្លួនស្មើរនឹងព្រះជាម្ចាស់ បានជាពោលពាក្យនេះ! មានតែព្រះជាម្ចាស់មួយព្រះអង្គទេដែលអាចអត់ទោសអោយមនុស្សរួចពីបាបបាន! ព្រះយេស៊ូដឹងអំពីគំនិតរបស់អ្នកទាំងនោះ ទើបព្រះអង្គនិយាយថា៖ «ម៉េចក៏អ្នករាល់គ្នានឹកគិតអញ្ចឹង? បើខ្ញុំប្រាប់អ្នកខ្វិននេះថា "ខ្ញុំអត់ទោសអោយអ្នករួចពីបាបហើយ" ឬថា "ចូរក្រោកឡើងដើរទៅចុះ" តើឃ្លាមួយណាស្រួលនិយាយជាង?។ ប៉ុន្តែខ្ញុំចង់អោយអ្នករាល់គ្នាដឹងថា ខ្ញុំមានអំណាចនឹងអត់ទោសអោយមនុស្សនៅក្នុងលោកនេះរួចពីបាបបាន» ព្រះអង្គក៏ងាកទៅរកអ្នកខ្វិន ហើយនិយាយថា៖ «ចូរក្រោកឡើង យកគ្រែស្នែងដើរទៅផ្ទះវិញទៅ»។ រំពេចនោះ អ្នកខ្វិនក្រោកឡើងនៅមុខមនុស្សទាំងអស់ រួចយកគ្រែស្នែងដែលគេសែងខ្លួនមក ដើរត្រលប់ទៅផ្ទះវិញ ទាំងសរសើរព្រះជាម្ចាស់ផង។

អស់អ្នកដែលនៅទីនោះ រន្ធត់ញាប់ញ័រគ្រប់គ្នា ហើយសរសើរនិង លើកតម្កើងព្រះជាម្ចាស់។ គេភ័យខ្លាចជាខ្លាំង ក៏និយាយគ្នាថា៖ «ថ្ងៃនេះ យើងបានឃើញការណ៍ចំឡែកអស្ចារ្យមែន!»។

## ២០៤ ព្រះយេស៊ូមានអំណាចលើជំងឺនិងសេចក្ដីស្លាប់

ម៉ាកុស ៥:២១-៤៣

នៅពេលព្រះយេស៊ូនៅបង្រៀនមនុស្ស និង មើលអ្នកជំងឺអោយបានជានៅឡើយ ក៏មានបុរសម្នាក់ដែលទទួលខុសត្រូវលើសាលាប្រជុំឈ្មោះយ៉ៃរ៉ូសមកដល់។ កាលគាត់ឃើញព្រះយេស៊ូ គាត់លុតជង្គង់នៅមុខព្រះអង្គ ទាំងអង្វរថា៖ «កូនស្រីរបស់ខ្ញុំឈឺធ្ងន់ជិតស្លាប់ហើយ! សូមមេត្តាមកដាក់ដៃលើគាត់ អោយគាត់បានជានិងមានជីវិត»។ ព្រះយេស៊ូក៏ទៅជាមួយគាត់។ មានមនុស្សជាច្រើនតាមព្រះអង្គទៅ ទាំងរុញគ្នាចោមរោមព្រះអង្គ។

នៅពេលនោះ មានស្ត្រីម្នាក់កើតជំងឺធ្លាក់ឈាមដប់ពីរឆ្នាំមកហើយ។ គ្រូពេទ្យជាច្រើនបានខំមើលនាង តែនាងឈឺចុកចាប់រឹតតែខ្លាំង។ នាងបានចំណាយទ្រព្យសម្បត្តិទាំងអស់ដែលនាងមាន តែជំងឺរបស់នាងកាន់តែខ្លាំងឡើងៗ ។ នាងបានឮគេនិយាយអំពីព្រះយេស៊ូ ដូច្នេះនាងក៏គិតថា៖ «បើខ្ញុំបានពាល់អាវរបស់លោកខ្ញុំមុខជានឹងបានជាមិនខាន!»។ ដូច្នេះនាងក៏រុញចូលហ្វូងមនុស្សនិងពាល់អាវរបស់ព្រះអង្គពីខាងក្រោយ។

រំពេចនោះ ឈាមឈប់ធ្លាក់ភ្លាម ហើយនាងដឹងថាខ្លួននាងបានជាសះស្បើយហើយ។ នៅពេលនោះ ព្រះយេស៊ូដឹងភ្លាមថាអំណាចមួយបានចេញពីព្រះអង្គហើយ ក៏សួរមនុស្សថា៖ «អ្នកណាពាល់អាវខ្ញុំ?»។ ពួកសិស្សឆ្លើយថា៖ «ព្រះអង្គឃើញស្រាប់ហើយ មនុស្សប្រជ្រៀតប៉ះនឹងព្រះអង្គគ្រប់គ្នា ម៉េចក៏សួរថា អ្នកណាពាល់អាវព្រះអង្គដូច្នេះ?» ព្រះយេស៊ូសំឡឹងមើលជុំវិញ ក៏ឃើញស្ត្រីនោះភ័យញ័ររន្ធត់ ព្រោះនាងដឹងអំពីអ្វីដែលកើតដល់ខ្លួននាង។ នាងលុតជង្គង់និងប្រាប់រឿងទាំងអស់ដល់ព្រះអង្គ។ ព្រះយេស៊ូប្រាប់នាងថា៖ «កូនស្រីអើយ! ជំនឿរបស់នាងបានធ្វើអោយនាងជាហើយ អញ្ជើញទៅ ទាំងជាសះស្បើយពីជំងឺចុះ!»

កាលព្រះយេស៊ូនៅនិយាយនៅឡើយ មានគេពីផ្ទះយ៉ៃរ៉ូសជំរាបគាត់ថា៖ «កូនស្រីលោកស្លាប់ហើយ កុំរំខានលោកគ្រូទៀត»។ ព្រះយេស៊ូមិនអើពើនឹងពាក្យរបស់គេ តែនិយាយទៅលោកយ៉ៃរ៉ូសថា៖ «កុំខ្លាចអី គ្រាន់តែជឿប៉ុណ្ណោះបានហើយ»។ ពេលទៅដល់ផ្ទះយ៉ៃរ៉ូសហើយ ព្រះយេស៊ូមិនអនុញ្ញាតអោយអ្នកណាទៅតាមព្រះអង្គឡើយ លើកលែងតែសិស្សបីនាក់ គឺពេត្រុស យ៉ូហាន និង យ៉ាកុប។ ព្រះយេស៊ូចូលផ្ទះ ហើយឃើញមនុស្សជ្រួលច្របល់និងទ្រហោយំជាខ្លាំង ក៏និយាយថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នាជ្រួលច្របល់និងទ្រហោយំអញ្ចឹង? ក្មេងនេះមិនស្លាប់ទេ នាងគ្រាន់តែដេកលក់ទេតើ!»។ ពួកគេចំអកដាក់ព្រះអង្គ ព្រះអង្គក៏ដេញគេអោយចេញទៅក្រៅទាំងអស់គ្នា រួចនាំតែឪពុកម្ដាយក្មេងនិងសិស្សបីនាក់ ចូលទៅក្នុងបន្ទប់ដែលក្មេងស្រីនោះដេក។

ព្រះយេស៊ូចាប់ដៃក្មេង ដែលមានអាយុ១២ឆ្នាំនោះ ហើយ
និយាយថា៖ «នាងតូចអើយ ចូរក្រោកឡើង!»។ ក្មេងស្រីក៏
ក្រោកឡើងដើរភ្លាម។ គេឆ្ងល់ខ្លាំងមែនទែន! តែព្រះយេស៊ូហាម
គេមិនអោយប្រាប់នរណាដឹងរឿងនេះឡើយ។

## ២០៥ ព្រះយេស៊ូប្រគល់ជីវិតនៅលើឈើឆ្កាង

លូកា ២៣:២៤,៣២-៥៦

លំនាំរឿង :

កាលព្រះយេស៊ូធំឡើងហើយ ព្រះអង្គបានបញ្ជាក់ម្តង ហើយម្តងទៀតថា ព្រះអង្គជាព្រះជាម្ចាស់ពិតប្រាកដមែន។ ព្រះយេស៊ូបានធ្វើការអស្ចារ្យនិងទីសំគាល់ផ្សេងៗជាច្រើន ដែលបង្ហាញថាព្រះអង្គពិតជាព្រះជាម្ចាស់ ព្រមទាំងបង្រៀនមនុស្សអំពីផ្លូវអោយរួចពីបាប និង អំពីអាណាចក្ររបស់ព្រះអង្គទៀតផង។

ទោះបីជាព្រះអង្គធ្វើការល្អដល់មនុស្សគ្រប់ពេលវេលាក៏ដោយ ក៏មេសាសនាទាស់ចិត្តនឹងព្រះអង្គដោយច្រណែននឹងការដែលរាស្ត្រស្រឡាញ់និងរាប់អានព្រះយេស៊ូយ៉ាងខ្លាំង។ ដូច្នេះ ពួកគេរួមគំនិតសំលាប់ព្រះអង្គ ដោយចោតថាព្រះអង្គជាអ្នកក្បត់ជាតិដែលដឹកនាំការបះបោរមួយ។ លោកពីឡាតដែលជាចៅហ្វាយក្រុងយេរូសាឡឹម បានយល់ព្រមធ្វើតាមពាក្យទាមទាររបស់ពួកមេសាសនា រួចបញ្ជាពួកទាហានរបស់គាត់អោយវាយព្រះយេស៊ូនិងដំដែកគោលលើដៃនិងជើងព្រះអង្គអោយផ្ជាប់នឹងឈើឆ្កាងតែម្តង នោះដើម្បីប្រហារជីវិតព្រះអង្គ។

ពួកទាហានរបស់លោកចៅហ្វាយក្រុង នាំព្រះយេស៊ូទៅក្នុងទីធ្លាបន្ទាយ ហើយមកចោមរោមព្រះអង្គ។ គេដោះអាវធំចេញ រួចយកអាវធំពណ៌ក្រហមទុំ មកបំពាក់អោយព្រះអង្គ។ គេយកបន្លាមកក្រងធ្វើជាភួងបំពាក់លើក្បាលព្រះអង្គ និង យកដំបងមកដាក់ក្នុងដៃស្តាំអោយព្រះអង្គកាន់ រួចគេនាំគ្នាលុតជង្គង់នៅមុខព្រះអង្គទាំងពោលចំអកថា៖ «ជយោស្តេច!»។ គេស្តោះទឹកមាត់ដាក់ព្រះអង្គ និង យកដំបងនោះវាយក្បាលព្រះអង្គទៀតផង។ ដល់ពេលហើយ គេដោះអាវធំចេញ យកអាវរបស់ព្រះអង្គមកបំពាក់អោយព្រះអង្គវិញ រួចបណ្តើរនាំយកទៅឆ្កាង។

ព្រះយេស៊ូលីឈើឆ្កាងដោយផ្ទាល់ខ្លួនចេញពីទីក្រុង ឆ្ពោះទៅកន្លែងមួយឈ្មោះ «ភ្នំលលាដ៏ក្បាល»។ ពេលទៅដល់កន្លែងគេឆ្កាងព្រះយេស៊ូរួចហើយ ពួកទាហានយកខោអាវរបស់ព្រះអង្គមកចាប់ឆ្នោតចែកគ្នា រួចអង្គុយយាមព្រះអង្គនៅទីនោះ។ គេបានឆ្កាងចោរព្រៃពីរនាក់ជាមួយព្រះយេស៊ូដែរ ម្នាក់នៅខាងស្តាំ ម្នាក់ទៀតនៅខាងឆ្វេង។

មនុស្សម្នានិងពួកមេសាសនាដើរកាត់តាមនោះ ប្រមាថមើលងាយព្រះអង្គ គ្រវីក្បាលដាក់ព្រះអង្គ ទាំងពោលថា៖ «ចូរសង្គ្រោះខ្លួនឯងទៅ! បើអ្នកពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន អញ្ជើញចុះពីឈើឆ្កាងមក! ពីព្រោះគាត់ពោលថា "ខ្ញុំជា

ព្រះបុត្រារបស់ព្រះជាម្ចាស់ "»។ សូម្បីតែចោរព្រៃដែលឆ្កាងជាមួយព្រះយេស៊ូ ក៏ជេរប្រមាថព្រះអង្គអញ្ចឹងដែរ។

ផែនដីទាំងមូលងងឹតសូន្យ ចាប់ពីពេលថ្ងៃត្រង់រហូតដល់ម៉ោងបីរសៀល។ ព្រះយេស៊ូស្រែកយ៉ាងខ្លាំង រួចផុតដង្ហើមទៅ។ ពេលនោះ វាំងននទៅក្នុងព្រះវិហាររហែកជាពីរ តាំងពីលើចុះមកក្រោម ផែនដីក៏រញ្ជួយ ផ្ទាំងថ្មក៏ប្រេះចេញពីគ្នា ផ្នូរក៏របើកចំហឡើង ហើយសាកសពមនុស្សល្អជាច្រើនបានរស់ឡើងវិញ និងនាំគ្នាចេញពីផ្នូរ!

កាលមេទាហាននិងពួកទាហានដែលនៅយាមព្រះយេស៊ូ បានឃើញផែនដីរញ្ជួយ និង បានឃើញការណ៍ទាំងអស់នេះកើតឡើងដូច្នេះ គេក៏កោតខ្លាចជាខ្លាំង ហើយនិយាយថា៖ «លោកនេះពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន!»។

# ២០៦ ព្រះជាម្ចាស់លើកព្រះយេស៊ូអោយមានជីវិតរស់ឡើងវិញ

ម៉ាថាយ ២៧:៥៧-២៨:១៥, ម៉ាកុស ១៥:១-២, ១៦:១០-១៤, លូកា ២៤:៣៧_៤២

ក្រោយព្រះយេស៊ូស្លាប់នៅពេលល្ងាចនោះ មានសេដ្ឋីម្នាក់ឈ្មោះយ៉ូសែបជាមនុស្សល្អនិងមានគេរ្តិ៍ឈ្មោះល្អផង ក៏ហានទៅជួបលោកចៅហ្វាយក្រុង សុំយកសពព្រះយេស៊ូ។ លោកពីឡាតក៏បញ្ជាអោយគេប្រគល់សពមកគាត់។ លោកយ៉ូសែបយកសពមករុំនឹងក្រណាត់ថ្មី រួចដាក់ក្នុងផ្នូរថ្មីរបស់គាត់ ជារូងថ្មដែលគេដាប់ធ្វើផ្នូរ។ បន្ទាប់មក គាត់ប្រមៀលថ្មមួយដុំធំបិតមាត់ផ្នូរ ហើយចាកចេញទៅ។ ស្ត្រីពីរនាក់ដែលជាសិស្សព្រះយេស៊ូក៏នៅទីនោះដែរ នាងអង្គុយនៅមុខផ្នូរ។

នៅថ្ងៃបន្ទាប់ មេសាសនានាំគ្នាទៅប្រាប់លោកពីឡាតថា៖ «យើងខ្ញុំនៅចាំពាក្យរបស់ជនបោកប្រាស់នោះ កាលពីគាត់នៅរស់ថាៈ "បីថ្ងៃក្រោយខ្ញុំស្លាប់ ខ្ញុំនឹងមានជីវិតរស់ឡើងវិញ "។ ហេតុនេះ សូមលោកបញ្ជាអោយគេយាមផ្នូរនោះ រហូតដល់ថ្ងៃទីបីទៅ ក្រែងលោសិស្សរបស់គាត់មកលួចយកសព ហើយប្រាប់មនុស្សថាគាត់រស់ឡើងវិញ»។ លោកពីឡាតពោលទៅគេថា៖ «អស់លោកមានទាហានស្រាប់ហើយ សុំអញ្ជើញទៅចាត់ចែងអោយគេយាមផ្នូរចុះ!»។ ពួកគេក៏នាំគ្នាចេញទៅផ្ទិតផ្នូរ បោះត្រាពីលើ និង ដាក់ទាហានអោយនៅយាមផង។

ព្រលឹមឡើងថ្ងៃអាទិត្យ ស្ត្រីបីនាក់ដែលជាសិស្សព្រះយេស៊ូ បានទិញគ្រឿងក្រអូបយកទៅអប់សពព្រះយេស៊ូ។ នៅពេលថ្ងៃរះ ពួកនាងកំពុងដើរទៅកាន់ផ្នូរ ក៏និយាយគ្នាថា៖ «តើបាននរណាជួយប្រមៀលថ្មចេញពីមាត់ផ្នូរអោយយើង?»។ ពេលនោះ ស្រាប់តែផែនដីរញ្ជួយយ៉ាងខ្លាំង ដោយមានទេវតារបស់ព្រះជាម្ចាស់ចុះពីស្ថានសួគ៌មកប្រមៀលថ្មចេញពីមាត់ផ្នូរ ហើយអង្គុយលើថ្មនោះតែម្តង! ទាហានភ័យញ័រជាខ្លាំង ហើយដួលដូចមនុស្សស្លាប់! ទេវតានិយាយប្រាប់ស្ត្រីៗថា៖ «កុំភ័យខ្លាចអី! ខ្ញុំដឹងថានាងៗមករកព្រះយេស៊ូដែលគេបានឆ្កាង ព្រះអង្គមិននៅទីនេះទេ! ព្រះជាម្ចាស់បានលើកព្រះអង្គអោយមានជីវិតរស់ឡើងវិញ ដូចព្រះអង្គប្រាប់រួចមកហើយ សុំមកមើលកន្លែងដែលគេដាក់សពព្រះអង្គឯណេះសិន រួចហើយទៅប្រាប់ពួកសិស្សរបស់ព្រះអង្គជាប្រញាប់ថាព្រះអង្គមានជីវិតរស់ឡើងវិញហើយ!»។

ពួកស្ត្រីរត់ចេញពីផ្នូរទាំងភ័យទាំងអរយ៉ាងខ្លាំង នាំដំណឹងនេះទៅប្រាប់ពួកសិស្ស។ ពេលនោះ ស្រាប់តែព្រះយេស៊ូមកជួបពួកនាង ហើយនិយាយថា៖ «ជំរាបសួរនាង!»។ ពួកនាងក៏មកអោបជើង

និងក្រាបគោរពព្រះអង្គ។ ព្រះយេស៊ូនិយាយថា៖ «កុំភ័យខ្លាចអ្វីឡើយ! សុំទៅប្រាប់បងប្អូនខ្ញុំថាគេនឹងឃើញខ្ញុំដែរ»។

ពួកនាងបានយកដំណឹងនេះទៅប្រាប់អស់អ្នកដែលនៅជាមួយព្រះយេស៊ូកាលពីមុន។ អ្នកទាំងនោះកំពុងកាន់ទុក្ខនិងយំសោកទៀតផង។ ពេលគេឮថាព្រះយេស៊ូមានជីវិតរស់ឡើងវិញហើយ ហើយឮថាពួកនាងបានឃើញព្រះអង្គ គេមិនជឿទេ។ បន្ទាប់មកព្រះយេស៊ូបានបង្ហាញខ្លួនអោយសិស្សរបស់ព្រះអង្គឃើញ នៅពេលដែលគេកំពុងហូបបាយ។ ពួកគេអរផង ហើយភ័យរន្ធត់ចិត្តផង ព្រះអង្គបន្ទោសគេ ព្រោះគេអត់ជឿអស់អ្នកដែលឃើញព្រះអង្គមានជីវិតរស់ឡើងវិញទេ។ ព្រះយេស៊ូសួរគេថា៖ «ហេតុអ្វីបានជាអ្នករាល់គ្នារន្ធត់ចិត្តអញ្ចឹង? ម្ដេចក៏អ្នករាល់គ្នានៅសង្ស័យ? ចូរមើលដៃជើងខ្ញុំ គឺពិតជាខ្ញុំមែន! ចូរស្ទាបមើល៍ ខ្មោចគ្មានសាច់គ្មានឆ្អឹងដូចខ្ញុំទេ»។ រួចហើយព្រះអង្គក៏បង្ហាញដៃនិងជើងអោយគេឃើញ បន្ទាប់មកព្រះយេស៊ូញាំុត្រីអាំងជាមួយគេតែម្ដង!

# ២០៧ ព្រះយេស៊ូឡើងទៅស្ថានសួគ៌

កិច្ចការ ១, ម៉ាថាយ ២៤_២៨, ម៉ាកុស ១៦, លូកា ២១

ក្នុងរយៈពេល៤០ថ្ងៃ ក្រោយពេលព្រះយេស៊ូរងទុក្ខលំបាកហើយ ព្រះអង្គបានបង្ហាញខ្លួន អោយពួកសិស្សព្រះអង្គទាំងអស់គ្នាឃើញថា ព្រះអង្គមានជីវិតរស់ឡើងវិញពិតប្រាកដមែន។ នៅថ្ងៃចុងក្រោយនោះ ព្រះអង្គបង្រៀនពួកគេអំពីរាជ្យរបស់ស្ថានសួគ៌។

ព្រះយេស៊ូបានផ្ទុកផ្តាក់ពួកសិស្ស អោយធ្វើជាទូតនៃរាជ្យរបស់ព្រះជាម្ចាស់ដោយបង្គាប់គេថា៖ «ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសិស្សខ្ញុំ ហើយជ្រមុជគេក្នុងទឹក ក្នុងនាមព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណ ហើយបង្រៀនគេអោយធ្វើតាមអ្វីៗទាំងអស់ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។ អ្នកណាជឿ ហើយបានជ្រមុជក្នុងទឹក ព្រះជាម្ចាស់នឹងលើកលែងទោសអោយអ្នកនោះ រីឯអ្នកដែលមិនជឿវិញ នឹងត្រូវទទួលទោស»។

ពួកសិស្សដែលជាទូតព្រះអង្គឆ្ងល់ ហើយសួរព្រះយេស៊ូថា៖ «តើព្រះអង្គមិនរៀបចំរាជ្យរបស់ព្រះអង្គនៅលើផែនដីនៅពេលនេះទេឬ?» ព្រះអង្គឆ្លើយថា៖ «ទេ មានតែព្រះបិតាដែលដឹងពេលវេលាដែលព្រះអង្គបានកំណត់ទុក ប៉ុន្តែអំណាចនៃព្រះវិញ្ញាណនឹងមកបំពេញអ្នករាល់គ្នា រួចហើយអ្នកនឹងធ្វើជាសាក្សីអំពីខ្ញុំនៅគ្រប់ទីកន្លែងនៅលើផែនដី។ អស់អ្នកដែលជឿនឹងធ្វើទីសំគាល់ទាំងនេះ គេនឹងដេញខ្មោចក្នុងនាមខ្ញុំ គេនឹងនិយាយភាសាថ្មី គេនឹងមិនមានគ្រោះថ្នាក់ដោយពស់ចឹកឬដោយផឹកអ្វីដែលមានជាតិពុល ហើយគេនឹងដាក់ដៃលើអ្នកជំងឺ ហើយអ្នកនោះនឹងបានជាសះស្បើយ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃរហូតដល់ចុងបញ្ចប់នៃគ្រានេះ»។

ពេលព្រះយេស៊ូនិយាយចប់ហើយ ពួកទូតរបស់ព្រះអង្គសំឡឹងមើលព្រះអង្គ ស្រាប់តែព្រះជាម្ចាស់លើកព្រះអង្គឡើងទៅលើមេឃ ហើយពពកមកបាំងព្រះអង្គបាត់ពីភ្នែកគេទៅ។ នៅពេលដែលគេនៅមើលលើមេឃនៅឡើយ ស្រាប់តែមានបុរសពីនាក់ស្លៀកសពាក់សចូលមកជិតគេ ហើយនិយាយថា៖ «ម្តេចក៏នៅតែឈរសំឡឹងមើលទៅលើមេឃអញ្ចឹង? ព្រះយេស៊ូនឹងត្រឡប់មកវិញ តាមរបៀបដូចដែលព្រះអង្គឡើងទៅស្ថានសួគ៌ដែរ»។

កាលគេឮពាក្យរបស់ទេវតានោះ ពួកសិស្សនឹកចាំអំពីអ្វីដែលព្រះយេស៊ូបានបង្រៀនគេរួចហើយ។ ព្រះយេស៊ូបានទាយថា៖ «ប្រទេសមួយនឹងធ្វើសង្គ្រាមតទល់នឹងប្រទេសមួយទៀត នៅតំបន់ផ្សេងៗនឹងមានកើតគ្រោះអាសន្ន គ្រោះអត់ឃ្លាននិងរញ្ជួយផែនដី។ មនុស្សទាំងអស់នឹងតឹងទ្រូង ព្រួយបារម្ភពេលឮសូរសន្ធឹករលកសមុទ្របក់បោក ហើយភ័យស្លុតដោយឃើញការណ៍អស្ចារ្យផ្សេងៗកើតឡើង។ អំពើអាក្រក់នឹងរីកចំរើនឡើងជាខ្លាំង។ ទោះជាគេជួបនឹងការបៀតបៀនយ៉ាងខ្លាំងក៏ដោយ ក៏អ្នកបំរើ

របស់ខ្ញុំ នឹងប្រកាសដំណឹងល្អពាសពេញសកលលោកទាំងមូល រួចហើយ ខ្ញុំនឹងត្រឡប់មកវិញ។ ខ្ញុំនឹងមកវិញ ប្រៀបដូចជាផ្លេកបន្ទោរភ្លឺឆ្វាច គេនឹងឃើញខ្ញុំមកលើពពកក្នុងផ្ទៃមេឃ ពេញទៅដោយអំណាចស័ក្ដិសិទ្ធ និងសេរីរុងរឿងដ៏អស្ចារ្យ»។

«ពេលនោះ នឹងមានសំឡេងត្រែលាន់ឮរំពងឡើង ខ្ញុំក៏នឹងចាត់ទេវតាអោយទៅប្រមូលពួកអ្នកដែលព្រះជាម្ចាស់បានជ្រើសរើសចាប់ពីជើងមេឃម្ខាង ទៅជើងមេឃម្ខាង។ នៅពេលនោះ ខ្ញុំនឹងអង្គុយនៅលើបល្ល័ង្ករុងរឿង ហើយមនុស្សគ្រប់ជាតិសាសន៍នឹងមកផ្ដុំគ្នានៅមុខខ្ញុំ ខ្ញុំនឹងកាត់ក្ដីអោយមនុស្សទាំងអស់ ដោយញែកគេចេញពីគ្នា គឺអោយអ្នកជឿដែលព្រះបិតាបានសង្គ្រោះនៅខាងស្ដាំ និងមនុស្សមិនព្រមជឿ ដែលមានទោសនៅខាងឆ្វេង។ ចំពោះអ្នកជឿ ខ្ញុំនឹងនិយាយថា, "ចូរនាំគ្នាចូលរាជ្យនៃស្ថានសួគ៌ ដែលខ្ញុំបានរៀបទុកអោយអ្នករាល់គ្នា តាំងពីកំណើតពិភពលោកមក"។ ចំពោះអ្នកមិនជឿវិញ ខ្ញុំនឹងនិយាយថា, "ចូរថយចេញអោយឆ្ងាយពីយើង ហើយធ្លាក់ទៅក្នុងបឹងភ្លើងដែលឆេះរហូតតរៀងទៅ ជាភ្លើងរៀបទុកសំរាប់កាត់ទោសមារសាតាំង និងទេវតារបស់វានោះទៅ! "»។

ពួកសិស្សដែលជាទូតរបស់ព្រះយេស៊ូនាំគ្នាវិលត្រឡប់ទៅក្រុងយេរូសាឡឹមវិញ ទាំងឆ្ងល់និងរំភើពយ៉ាងខ្លាំង នោះដើម្បីរង់ចាំអំណាចនៃព្រះវិញ្ញាណ សំរាប់ផ្សាយដំណឹងល្អនៅគ្រប់ទីកន្លែង។